**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៤៣៥ ព.ណ.ក.ស.ប

ថ្ងៃច័ន្ទ ១កើត ខែមាឃ ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកុម្ភៈ ឆ្នាំ ២០២៣

## ជម្រាបមក

**លោក/លោកស្រីប្រធាន ក្រុមហ៊ុន តូយ៉ូតា** ( **ខេមបូឌា** )

**កម្មវត្ថុ:** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើយានយន្ត និងគ្រឿងបន្លាស់ម៉ាក "COROLLA", "HIACE", "COASTER", "LANDCRUISER", "HILUX" និង "CAMRY" ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **តូយ៉ូតា** ( **ខេមបូឌា** )។

**យោង:** - មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតបន្តរបស់ក្រុមហ៊ុន **តូយ៉ូតា** ( **ខេមបូឌា** ) ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០២២
- លិខិតកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខលេខ ០១២៣ ព.ណ កសប ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២១
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន TOYOTA JIDOSHA KABUSHIKI KAISHA ( TOYOTA MOTOR CORPORATION ) ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩៤៨/៩២ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩៤២/៩២ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩៤១/៩២ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩៤៥/៩២ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩៤៣/៩២ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៩៥២/៩២ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើយានយន្ត និងគ្រឿងបន្លាស់ពាក់ម៉ាកខាងលើ ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **តូយ៉ូតា** ( **ខេមបូឌា** ) ដែលទទួលបានពីក្រុមហ៊ុន TOYOTA JIDOSHA KABUSHIKI KAISHA ( TOYOTA MOTOR CORPORATION ) ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូលផ្តាច់មុខរបស់ម្ចាស់ម៉ាកដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតបន្តសុពលភាពកត់ត្រានេះ មានសុពលភាព ០២ (ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០២២ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន TOYOTA JIDOSHA KABUSHIKI KAISHA ( TOYOTA MOTOR CORPORATION ) ដែលជាម្ចាស់ម៉ាក។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រាជ**

*__ចម្លងជូន:__*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

# បញ្ជី

## ម៉ូឌែលភ្ជាប់ និងលិខិតកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ

## ម៉ាក "TOYOTA"

| ល.រ | ឈ្មោះ ម៉ូដែល "TOYOTA" |
|---|---|
| 1 | COROLLA |
| 2 | HIACE |
| 3 | COASTER |
| 4 | LANDCRUISER |
| 5 | HILUX |
| 6 | CAMRY |